# សម្មតិកម្មបឋមស្តីអំពី ភ្នំបូកនិងឈ្មោះដើម

ក្នុងរាជ្យព្រះបាទយសោវរ្ម័នទី១ (៨៨៩គ.សដល់៩១០គ.ស) ព្រះអង្គបានផ្លាស់រាជធានីពី**នគរហរិហរាល័យ** ដែលស្ថាបនាឡើងតាំងពីរាជ្យព្រះបាទជ័យវរ្ម័នទី២ (៨០២គ.សដល់៨៣៦គ.ស) និងបន្តគង់នៅដោយព្រះបាទជ័យវរ្ម័នទី៣ (៨៣៦គ.សដល់៨៧៧គ.ស) និងព្រះបាទឥន្ទ្រវរ្ម័នទី១ (គ.ស៨៧៧ដល់៨៨៩គ.ស) ទៅ**យសោធរបុរៈ** ដែលជារាជធានីថ្មីរបស់ព្រះអង្គ។ ព្រះអង្គបានប្រសិទ្ធិនាមព្រះរាជធានីថ្មី ហៅថា **យសោធរបុរៈ**[១] ដោយមានភ្នំមួយជាផ្ចិតកណ្តាលនៃរាជធានី ឈ្មោះហៅថា **យសោធរគិរិ** (ជាភាសាសំស្ក្រឹត) ឬហៅថា **វ្នំកន្តាល** (ភាសាខ្មែរបុរាណ)។ ព្រះអង្គបានស្ថាបនាប្រាសាទដ៏ធំមួយនៅលើកំពូលភ្នំ (ធម្មជាតិ) នោះ ដែលសព្វថ្ងៃមានឈ្មោះថា **ប្រាសាទភ្នំបាខែង** តំណាងឱ្យរាជ្យរបស់ព្រះអង្គ (រូបលេខ១)។ ក្រៅពីនេះ ព្រះអង្គបានស្ថាបនាប្រាសាទ២ទៀតនៅលើកំពូលភ្នំ២ផ្សេងគ្នាដែរ។ ប្រាសាទទី១ មានទីតាំងស្ថិតនៅខាងត្បូងរាជធានី គឺ**ប្រាសាទភ្នំក្រោម** (ឧទ្ទិសដល់ទេពត្រិមូត្តិ) ដែលភ្នំនេះមានឈ្មោះដើមជាភាសាខ្មែរហៅថា **វ្នំករោម**[២] (K.262) តែពុំមានឈ្មោះជាភាសាសំស្ក្រឹតនោះទេ។ ប្រាសាទមួយទៀតស្ថិតនៅភាគឥសាន្តនៃនគរ**យសោធរបុរៈ** ដែលគេស្គាល់ថា **ប្រាសាទភ្នំបូក**។ បើយើងពិនិត្យមើលទីតាំងភ្នំទាំង៣ គឺវាបង្កើតបានជាចំនុច៣ ឬត្រីកោណ១ ដែលភ្នំបាខែងស្ថិតនៅចំកណ្តាល(កណ្តាល) ភ្នំក្រោមស្ថិតនៅខាងត្បូង(ក្រោម/ទាប) និងភ្នំបូកស្ថិតនៅខាងជើង(លើ/ខ្ពស់) ដូចនេះបានជាខ្មែរបុរាណហៅភ្នំបាខែងថា **ភ្នំកន្តាល** ព្រោះស្ថិតនៅកណ្តាលគេ ភ្នំក្រោមហៅថា ភ្នំករោម ព្រោះនៅខាងក្រោមទាបក្បែរមាត់បឹងទន្លេសាប និងភ្នំបូក(ខ្ពស់) នៅខាងលើ (រូបលេខ២)។ អ្វីដែលជាបញ្ហាសម្រាប់អ្នកស្រាវជ្រាវ គឺមកដល់សព្វថ្ងៃ ឈ្មោះដើមរបស់ភ្នំបូកនេះនៅមិនទាន់ដឹង និងមានការសិក្សាពន្យល់បកស្រាយនៅឡើយទេ។ **តើឈ្មោះដើមរបស់ភ្នំបូកមានដែរឬទេ?**

---

[១] Finot Louis 1932

[២] Coedès, G. 1952:112

អត្ថបទដោយៈ សុខ កែវ សុវណ្ណារ៉ា

តាមរយៈសិលាចារឹកស្តុកកក់ធំ K.235[៣] ផ្ទាំងD (រូបលេខ៣) ពីបន្ទាត់ទី១ដល់ទី១១ យើងអាចធ្វើការវិភាគលើពាក្យ និងឃ្លាមួយចំនួន ដែលអាចអោយយើងសន្និដ្ឋានអំពីឈ្មោះដើមរបស់ប្រាសាទភ្នំបូក។

*អត្ថបទសិលាចារឹកផ្ទាំង D ..... (៣) យ ស្រុក កុតិ០ ស្តេង អញ រុទ្រាចារ្យយ ត ផូន ស្តេង អញ គិវកៃវល្យ ទៅ ប្វាស* ***អាយ វិថយ ជេង វ្នំ ត វ្នំ ត ផ្ទះ ថ្កោ*** *០ ស្តេង (៤) អញ រុទ្រាចារ្យយ ស្វំ នោះ នុ ភូមិ នោះ ត វ្រះ បាទ វិស្ណុលោក ចត ស្រុក ស្ថាបនា ត គិ* ***ទុក ផ្ទះ វ្នំ នោះ ផ្ទះ ភទ្រគិរិ*** *០ ត គិ រាជ្យ (៥) វ្រះ បាទ ឥន្ទ្វរលោក កម្រតេង ជគត តរាជ នៅ ហរិហរាលយ កុលេ ផោង សិង អនៅ នា កម្រតេង ជគត ត រាជ រ ត តា ប្រ ៙ ស្តេ(៦)ង អញ វាមគិវ ថៅ ស្តេង អញ គិវកៃវល្យ ជា ឧបាធ្យាយ វ្រះ បាទ ឥន្ទ្វរលោក អោយ វ្រះ បាទ ឥន្ទ្វរលោក អោយ វ្រះ បាទ បរមគិវ(៧)លោក កាល កន្សេង លេយ ប្រេ បព្យាន ស្តេង អញ វាមគសិវ ជា គិឞ្យ ស្តេង អញ គិវសោម ត ជា គុរុ វ្រះ បាទ ឥន្ទ្វរលោក ស្តេ(៨)ង អញ គិវសោម នុ ស្តេង អញ វាមគិវ ស្បង ត ចត គិវគ្រម ស្ថាបនា វ្រះ នោះ ស្តេង អញ គិវសោម តិ អ្នក ហៅ កម្រតេង គិវគ្រម ចាស្ប (៩) ស្តេង អញ វាមគិវ តិ អ្នក ហៅ កម្រតេង គិវគ្រម កន្សេង មន ស្តេង អញ គិវសោម ស្វាប ស្តេង អញ វាមគិវ គិ នាក មាន គិវាគ្រម អ្នក ហៅ កម្រតេង គិ (១០)វាគ្រម ពោះហ នោះហ អ្នៅ០ មន វ្រះ បាទ បរមគិវលោក. . . វ្រះ កម្រតេង វាមគិវ ត ផ្ទះ កម្រតេង គិវគ្រម ជា វ្រះ គុរុ បរិបាលន ឧបាយ ផោង នុ វ្រះ (១១) ត តិ សន្តាន* ***ស្ថាបនា អំរិ ឥន្ទ្របុរ នា ស្រុក ភវាលយ ញ្យង អមរេន្ទ្របុរ ស្រុក កុតិ ប្វូវ៌ទិគ ស្រុក ភទ្រគិរិ ជេង វ្នំ*** *០ គិ កុលេ ផោង សិង នា........*

ក្នុងបន្ទាត់ទី៣ និងទី៤ បង្ហាញអំពីបុគ្គលឈ្មោះ **ស្តេងអញ រុទ្រាចារ្យយ** ដែលជាប្អូនរបស់ **ស្តេងអញ សិវកៃវល្យ** បានទៅបួសរៀននៅទីកន្លែងមួយឈ្មោះ ហៅថា **វិស័យជើងភ្នំឈ្មោះថ្កោ។**[៤] ក្រោយមក ស្តេងអញ រុទ្រាចារ្យយបានបង្គំសុំដី (ភូមិ) តំបន់នោះ ពី **ព្រះបាទវិស្ណុលោក** (ជ័យវរ្ម័នទី៣) ដើម្បីស្ថាបនាជាស្រុក ហើយដាក់ឈ្មោះអោយភ្នំនោះ

[៣] Finot Louis, 1915(2):53-106

[៤] តាមការចម្លងពីពាក្យដើមរបស់សិលាចារឹករបស់លោក Finot អានថា ថ្កោ។ ប៉ុន្តែលោក Chhany បានគិតថា ពាក្យនេះមិនច្បាស់ គឺអាចជា ផ្កោ។

*ថា **ភទ្រគិរិ**។ តាមរយៈឈ្មោះទីកន្លែងមួយចំនួនក្នុងបន្ទាត់ទី១១ យើងអាចគូសបង្ហាញខ្លះអំពីទីតាំងតំបន់ឬកន្លែងទាំងនោះ។ តាមព្រះរាជបញ្ជារបស់ព្រះបាទ **បរមគិរលោក** (យសោវរ្ម័នទី១) សន្តានរបស់ព្រះគ្រូ **កម្រតេងវាមគិរ** បានស្ដាបនាសំណង់នានានៅ **ឥន្ទ្របុរៈ** (បន្ទាយព្រៃនគរ កំពង់ចាម) និងស្រុក **ភវលយញ្យង**(?) **អមរេន្ទ្របុរៈ** (ក្បែរប្រាសាទអកយំ)[៥] ស្រុក **កុតិបូវ៌ទិស** (តំបន់ប្រាសាទបន្ទាយក្ដី) និងស្រុក **ភទ្រគិរិ ជេង វ្នំ**។ ក្នុងឃ្លាខាងលើរបស់អត្ថបទសិលាចារឹកនេះ យើងមានបញ្ហាមួយដែលត្រូវសិក្សាវែកញែក គឺៈ*

***ទី១ៈ** គឺពាក្យ ថ្កោ (Finot) ឬផ្ដោ (Chhany)[៦] ដែលមានបង្ហាញតែម្ដងគត់ក្នុងសិលាចារឹកស្ដុកកក់ធំ ក្នុងផ្ទាំង Dបន្ទាត់ទី៣។ ពាក្យនេះពុំមានបង្ហាញក្នុងសិលាចារឹកផ្សេងទេ ហើយបន្ទាប់ពីការសុំពីព្រះបាទជ័យវរ្ម័នទី៣ ដោយព្រាហ្មណ៍ឈ្មោះ**រុទ្រាចារ្យយ** នូវភូមិក្នុងតំបន់ភ្នំនោះ ហើយបានប្ដូរឈ្មោះភ្នំ ដោយដាក់ឈ្មោះថ្មីហៅថា **ភទ្រគិរិ** ហើយពាក្យឬឈ្មោះវ្នំថ្កោត្រូវបានឈប់ប្រើក្នុងឃ្លាក្រោយៗក្នុងសិលាចារឹកស្ដុកកក់ធំនេះ។ ពោលគឺគេប្រើតែឈ្មោះ **ភទ្រគិរិ** ពីរបីដងទៀតក្នុងសិលាចារឹកដដែល (ផ្ទាំង B បន្ទាត់ទី៩, ១៦ និង ៧០)។ ក្នុងផ្ទាំង B បន្ទាត់ទី៧០ ជាអត្ថបទភាសាសំស្ក្រឹត ហៅថា ភទ្រទ្រិ =ភទ្រគិរិ។*

*ទី២ៈ ពាក្យ **ថ្កោ** ឬឈ្មោះ **វ្នំថ្កោ** គឺអាចជាពាក្យចាស់មុនការយាងមកដល់របស់ព្រះបាទជ័យវរ្ម័នទី២ និងក្សត្រផ្សេងៗ រួមទាំងគ្រួសារព្រាហ្មណ៍ផងដែរ។ មនុស្សនៅតំបន់នោះស្គាល់និងហៅភ្នំនោះថា **វ្នំថ្កោ ឬផ្ដោ** មុនការស្ដាបនាស្រុកនៅទីនោះ ហើយកែឈ្មោះហៅភ្នំនោះថា **ភទ្រគិរិ**។*

*ទី៣ៈ **តើពាក្យ ថ្កោ ឬផ្ដោ មានន័យដូចម្ដេច?** ជាក់ស្ដែង ពាក្យនេះមានវត្តមានតែម្ដងគត់ក្នុងសិលាចារឹកនេះ។ វាមានក្នុងសិលាចារឹកសតវត្សទី១៣មួយផ្សេងទៀត K.241[៧] ជាឈ្មោះរបស់បុរសម្នាក់ហៅថា **សិ ថ្កោ** ។ អ្នកស្រី ពៅ សាវរស់[៨] ក៏មិនអាចពន្យល់អំពីអត្ថន័យរបស់ពាក្យនេះដែរ។ វត្តមានរបស់ពាក្យនេះមានតិចតួចពេកក្នុងសិលាចារឹក ហើយក៏មិន*

---

[៥] Lawrence Palmer Brigger 1951:49

[៦] Chhany Sak-Humphry 2005:111

[៧] Coedès, G., 1951:78

[៨] Pou, S. 1992:238

*អត្ថបទដោយៈ សុខ កែវ សុវណ្ណារ៉ា*

បង្ហាញអំពីអត្ថន័យរបស់ពាក្យនេះ វាជាមូលហេតុធ្វើអោយយើងពិបាកក្នុងការស្វែងយល់អំពីឫសគល់នៃពាក្យនេះណាស់។ ពាក្យនេះ អាចជាពាក្យកម្ចាយពីពាក្យ **តង្កោ** ដែលមានបង្ហាញក្នុងសិលាចារឹកពីរបីផ្សេងទៀត ដូចជា សិលាចារឹក K.184 (៩២១គ.ស) K.292 (១០១១គ.ស) និង K.206 (១០៤២គ.ស) ដែលមានន័យថាជាប្រភេទរុក្ខជាតិម្យ៉ាងសព្វថ្ងៃហៅថា **ដើមដង្កោ**[៩] អាចធ្វើជាគ្រឿងជ្រលក់ ឬធ្វើជាអាហារបាន។ ប៉ុន្តែពាក្យ តង្កោក្នុងសិលាចារឹកទាំង៣ផ្សេងនេះគ្រាន់តែឈ្មោះទីកន្លែងផ្សេង ពុំមានទាក់ទងនិងស្ថាននាម **វ្នំថ្កោ** នេះទេ។ ក្នុងករណីទី២ តាមការយល់របស់លោក Chhany ដែលពាក្យក្នុងសិលាចារឹកនេះ អាចជាពាក្យ **ផ្កោ** ដែលយើងស្ទើពុំមានក្នុងសិលាចារឹកដទៃឡើយ។ លោក Jenner[១០] គិតថា វាពាក្យ ឬភាសានិយាយនៃពាក្យ **ថ្កោ**។

ទី៤៖ យើងអាចសិក្សាលើទីតាំងដែលបានបង្ហាញក្នុងបន្ទាត់ទី១១ ដែលសន្តានរបស់ **កម្រតេង គិរគ្រម** បានស្ថាបនាអ្វីផ្សេងៗក្នុងតំបន់នោះ។ តំបន់ចុងក្រោយ២ ដែលយើងគួរពិចារណា គឺ **ស្រុកកុតិបូវ៌ទិស** និង**ស្រុកភទ្រគិរិជេងវ្នំ**។ ទីកន្លែងផ្សេងៗសុទ្ធសឹងតែនៅតំបន់ឆ្ងាយៗពីអង្គរ លើកលែងតែស្រុកកុតិបវ៌ទិស ដែលគេសន្និដ្ឋានថា ជាតំបន់ជុំវិញប្រាសាទបន្ទាយក្តីសព្វថ្ងៃ។ ស្រុកភទ្រគិរិដែលឈ្មោះដើមហៅថា វ្នំថ្កោឬផ្កោ ជាទីតាំងអាចនៅក្បែរនិងស្រុកកុដិដែរ ព្រោះកំស្តែងរុទ្រាចារ្យបានទៅបួសរៀននៅទីនោះ ដោយចាកចេញពីស្រុកកុដិទៅ។ ភ្នំដែលនៅក្បែរតំបន់នោះគឺអាចជាភ្នំបូកសព្វថ្ងៃ បើយើងគិតអំពីភ្នំដទៃទៀត គឺភ្នំបាខែង និងភ្នំក្រោម គឺមានឈ្មោះបង្ហាញស្រាប់ក្នុងអត្ថបទសិលាចារឹកជាមួយគ្នានេះ។

ទី៥៖ ក្នុងបន្ទាត់ទី៤៨និង៤៩ បង្ហាញអំពីកិច្ចការរបស់រាជបុរោហិត ឈ្មោះ កំស្តែងស្រី ជយេន្ទ្របណ្ឌិត នៅស្រុកភទ្រគិរិ ដោយធ្វើពិធីបើកព្រះនេត្របដិមាទេព និងស្ថាបនាស្រុកឡើងវិញ ដោយធ្វើទំនប់ ធ្វើវលយ (សំណង់មូលជារង្វង់) ធ្វើអគារអោយព្រះគោ (គោគាល)។ ទិដ្ឋភាពសព្វថ្ងៃជុំវិញភ្នំបូកនេះ ទោះជាមិនទាន់មានការស្រាវជ្រាវលម្អិត តែ

---

[៩] ជួន ណាត, ១៩៦៧:៣០១

[១០] Philip N. Jenner, 2009:224

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

*យើងឃើញថា នៅជើងភ្នំផ្នែកខាងកើតហាក់បីដូចជាទំនប់ដីដែលគេលើកនិងបុកបង្ហាប់ និងមានសំណង់ប្រាសាទ (លាក់នាង) នៅភាគឥសាន្ត ក្បែរជើងភ្នំទៀតផង។*

*ទី៦៖ យើងគិតឡើងវិញម្តងទៀតអំពីពាក្យ **ផ្កោ ឬផ្គោ**។ ក្នុងបន្ទាត់ទី២៩ និយាយអំពីការស្ថាបនាអគារ ឬសំណង់សម្រាប់ព្រះគោ គឺហាក់បីដូចជាទីកន្លែងនោះជាទីតាំងមួយមានសារសំខាន់សម្រាប់គោដែលមានជីវិត និងជាគោនៃការគោរពបូជា ឬក៏អាចជាគោថ្ម (បដិមា) ដែលមនុស្សនៅតំបន់នោះ និងគ្រួសារព្រាហ្មណ៍ទាំងនេះយកចិត្តទុកដាក់ក្នុងការថែរក្សា។ ពាក្យ **ផ្គោ** បើយើងនិយាយ ឬភាសារបស់មនុស្សក្នុងតំបន់ខ្លះ រមែងតែងនិយាយដាច់បំបាត់សម្លេងខ្លះ ឧទាហរណ៍ បើយើងនិយាយថា ស្អែកចង់ទៅមើលប្រាសាទព្រះគោ នោះពាក្យព្រះគោ អាចបញ្ចេញសំលេងតែ ផ្គោ (ប៉-គោ)។ បើនិយាយក្នុងលក្ខណៈមិនផ្លូវការមួយ ពាក្យ ផ្គោ អាចជាពាក្យនិយាយ (ខ្លី/ញាប់) របស់មនុស្សសំដៅលើពាក្យ ព្រះគោ (ផ្គោ=ផគោ>ព្រះគោ/វ្រះគោ)។*

*ទី៧៖ យើងពិនិត្យមើលលើពាក្យ ឬឈ្មោះបច្ចុប្បន្នរបស់ភ្នំនេះ គឺ **ភ្នំបូក**។ ពាក្យបូកមានន័យថា ខ្ពស់ ឬអ្វីដែលងើបផុតពីគេ។ អត្ថន័យទី២ គឺវាអាចទាក់ទងនិងភាពលយខ្ពស់នៃខ្នងសត្វគោ ដែលយើងហៅថា **បូកគោ**។ សព្វថ្ងៃមានជួរភ្នំមួយក្នុងខេត្តកំពត គេហៅថា **ភ្នំបូកគោ** ព្រោះរូបរាងនៃការសណ្ឋាកនៃជួរភ្នំនោះ មើលទៅរាងដូចបូកគោ។ ចំពោះភ្នំបូកក្នុងតំបន់អង្គរនេះវិញ គឺវាអាចមានន័យសំដៅទៅលើភ្នំដែលមានរាងដូចបូកគោដែរ តែមនុស្សសម័យមុន (ក្រោយអង្គរឬសម័យកណ្តាល) អាចហៅភ្នំនេះ ភ្នំបូក ព្រោះបើយើងសង្កេតមើលភ្នំនេះពីទិសខាងត្បូងឬនិរតី ឬឥសាន្ត យើងនិងឃើញភ្នំនេះមានរាងដូចបូកគោដែរ (រូបលេខ២៤)។*

*ទី៨៖ ចំនុចមួយទៀត ពាក្យ បូក នេះដដែលក៏អាចក្លាយមកពីពាក្យដើម ផ្គោ ដែរ។ នៅក្នុងទំនៀមទំលាប់ខ្មែរ ទោះជាភ្នំមួយ ឬប្រាសាទមួយត្រូវបានប្រសិទ្ធិនាមជាភាសាសំស្ក្រឹតក៏ដោយ តែខ្មែរនៅតែហៅឈ្មោះភ្នំឬប្រាសាទនោះ ជាឈ្មោះខ្មែរដដែល។ ឧទាហរណ៍សិលាចារឹកប្រាសាទត្រពាំងរពៅ* K.690[1] *និយាយពីការកំណត់ព្រំដីរបស់ប្រាសាទ និងការ*

[1] Coedès, G.(1964:91-93)

*អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា*

*ពិនិត្យមើលដី (ភូមិ) នៅ ភ្នំកណ្ដាល ។ ក្នុងករណីនេះ ទោះបីភ្នំផ្ដោ ត្រូវបានដូចឈ្មោះទៅជា ភ្នំភទ្រគិរិ ក៏ដោយ តែប្រជារាស្ត្រធម្មតានៅតែហៅឈ្មោះ ផ្ដោ ដដែល ហើយអាចបន្តរហូតមកដល់សម័យក្រោយអង្គរ ទោះពុំមានសិលាចារឹកបង្ហាញបញ្ជាក់ក៏ដោយ។ តើពាក្យ ផ្ដោ នេះអាចក្លាយមកជាពាក្យ បូក ឬទេ? វាអាចមាន២ករណី (១)គឺ ផ្ដោ=ផោក>ពោក>បូក (២) ផ្ដោ=ផកោ >បូកោ >បូកគោ>បូក។ នេះជាចំនុចវិភាគលើការវិវត្តន៍នៃពាក្យដែលអាចមានការប្រែប្រួលសម្លេង ឬការនិយាយរបស់មនុស្សផ្សេងគ្នា ឬសម័យកាលផ្សេងគ្នា។ ឧទាហរណ៍ ដូចជាឈ្មោះភូមិព្រះដាក់សព្វថ្ងៃ ដែលក្លាយពីពាក្យសម័យអង្គរយសោធរតដក>តដក>តាកាដ>បតក>ព្រះដាក់។*

*សរុបមក ចំនុចទាំងប៉ុន្មានខាងលើនេះ គ្រាន់តែជាពត៌មាននិងហេតុផលសម្រាប់បកស្រាយអំពីឈ្មោះដើមរបស់ភ្នំបូក ក្នុងតំបន់អង្គរសព្វថ្ងៃ។ យើងពុំមានពត៌មានលម្អិតច្រើនពីសិលាចារឹកសម័យអង្គរដែលបង្ហាញរៀបរាប់អោយដាក់ច្បាស់ថា ភ្នំបូកនេះដើមឡើយមានឈ្មោះអ្វីនោះទេ។*

*តាមរយ:សិលាចារឹកស្ដុកកក់ធំ និងសម្មតិកម្មមួយចំនួនដែលខ្ញុំបានបង្ហាញក្នុងចំនុចទាំង៨ខាងលើ ខ្ញុំសូមស្នើថា ឈ្មោះដើមរបស់ភ្នំបូក គឺអាចជា* ***វ្នំផ្ដោ/ផ្ដោ*** *ដែលបានបង្ហាញក្នុងបន្ទាត់ទី៤ ផ្ទាំងD ហើយក្រោយមកត្រូវបានកែទៅជា* ***ភទ្រគិរិ។***

---




រូបលេខ១១៖ ទីតាំងភ្នំបាខែង




រូបលេខ១២៖ ទីតាំងភ្នំទាំង៣ក្នុងតំបន់អង្គរ

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា




Sdok Kak Thom inscription, side D.

រូបលេខ៣៖ សិលាចារឹកស្តុកកក់ធំ ផ្ទាំង D (Chhany 2005)



រូបលេខ៤៖ ខ្នងភ្នំបូក មើលពីទិសឥសាន្ត

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

## ឯកសារយោង


ជួន ណាត, (១៩៦៧:៣០១), *វចនានុក្រមខ្មែរ*, ពុទ្ធសាសនបណ្ឌិត, ភ្នំពេញ។

Chhany Sak-Humphry

(2005), *The Sdok Kak Thom Inscription*, Buddhist Institute, Phnom Penh. Coedès, G., (1951), *Inscription du Cambodge*. Tome III, EFEO, Paris.

Coedès, G.,.

1952, *Inscription du Cambodge*, Tome IV, EFEO, Paris.

Coedès, G.

1964, *Inscription du Cambodge*, Tome VII, EFEO, Paris.

Finot Louis.

1915, *L'Inscription de Sdok Kak Thom*, BEFEO, Tome XV. Paris.

Finot Louis.

1932. *Le Yaçodharagiri et le Phimeanakas*, J.A. 220:47-59.

Lawrence Palmer Brigger.

1951. *The Ancient Khmer Empire*, Transactions of the American Philosophy Society.

Philip N. Jenner.

2009. *A Dictionary of Angkorian Khmer*, The Australian National University.

Pou, S.

1992. *An Old Khmer-French-English dictionary*. Paris: Cedorek.

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា